**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសទិវាសន្តិភាពអន្តរជាតិ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០

**សូមថ្វាយបង្គំ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ**
**ជនរួមជាតិជាទីស្នេហា**

ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០១ ជាទិវាប្រវត្តិសាស្ត្រដ៏វិសេសវិសាល ដែលមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៥៥ និងប្រទេសសមាជិកទាំងអស់បានអនុម័តជាឯកច្ឆន្ទកំណត់យកថ្ងៃទី២១ កញ្ញា ជាទិវាសន្តិភាពប្រចាំឆ្នាំដើម្បីឧទ្ទិសដល់ការបញ្ឈប់រាល់អរិភាព និងពង្រឹងឧត្តមគតិសន្តិភាពរបស់ប្រជាជាតិ និងប្រជាជនទាំងអស់នៅក្នុងពិភពលោក។ នៅក្នុងឆ្នាំ២០២០នេះ ការប្រារព្ធទិវាសន្តិភាពក្រោមមូលបទ "ការកសាងសន្តិភាពជាមួយគ្នា" បានប្រព្រឹត្តទៅទន្ទឹមគ្នានិងការប្រារព្ធខួបលើកទី៧៥ នៃអង្គការសហប្រជាជាតិ ដែលជាទិវាដ៏មានសារៈសំខាន់សម្រាប់សហគមន៍អន្តរជាតិ ក្នុងការសម្តែងចេញនូវសាមគ្គីភាព រួមគ្នាការពារពហុភាគីនិយម គោលបំណងនិងគោលការណ៍នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ដើម្បីសន្តិភាព សន្តិសុខ និងការអភិវឌ្ឍសម្រាប់មនុស្សជាតិ។

តាងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ សូមចូលរួមសម្តែងអំណរសាទរជាមួយបណ្តាប្រទេសសមាជិកអង្គការសហប្រជាជាតិទាំងអស់ ប្រារព្ធទិវាសន្តិភាពដ៏មហោឡារិកនេះ សំដៅលើកកម្ពស់ការយល់ដឹងពីអត្ថន័យនៃសន្តិភាពឱ្យកាន់តែទូលំទូលាយ ពង្រឹងសាមគ្គីភាពឯកភាពជាតិ បន្តជំរុញស្មារតី និងពួតដៃគ្នាជាធ្លុងមួយថែរក្សាឱ្យបានគង់វង្សនូវសុខសន្តិភាពយូរអង្វែងសម្រាប់កម្ពុជាយើងនិងពិភពលោកដើម្បីបោះជំហានបន្តទៅមុខលើវិថីអភិវឌ្ឍន៍ និងការរីកចម្រើន។

**ជនរួមជាតិជាទីស្នេហា**

កម្ពុជាទើបតែបានសុខសាន្ត រស់នៅក្នុងសុខសន្តិភាព និងឯកភាពជាតិពេញលេញ អស់រយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ ក្រោយពីការឆ្លងកាត់ភ្លក់ភ្លើងសង្គ្រាម ការបែកបាក់ និងទុក្ខវេទនាខ្លោចផ្សាកទីបំផុតគ្មាន ជាច្រើនសតវត្សកន្លងមកហើយនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ។ បទពិសោធន៍ដ៏ជូរចត់របស់កម្ពុជាពីអតីតកាល និងការអនុវត្តបានយ៉ាងជោគជ័យនូវ **«គោលនយោបាយ**

ឈ្នះ-ឈ្នះ» នៅឆ្នាំ១៩៩៨ បានធ្វើឱ្យប្រជាជនកម្ពុជាស្គាល់ច្បាស់ពីតម្លៃសន្តិភាព និងកាន់តែយល់ពីសារៈសំខាន់មិនអាចខ្វះបាននៃមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍ គឺសន្តិភាព និងស្ថិរភាព។

ដោយសារសន្តិភាពនេះហើយ ដែលកម្ពុជាមានឱកាសប្រឹងប្រែងងើបឈរដោយខ្លួនឯង ប្រកបដោយមោទនភាពបំផុត កសាងនិងអភិវឌ្ឍប្រទេសជាតិឡើងវិញ ធានាបាននូវបរិយាកាសអនុគ្រោះសម្រាប់លើកស្ទួយកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។ នៅក្នុងអំឡុងពេលជាងពីរទសវត្សរ៍កន្លងទៅ កំណើនសេដ្ឋកិច្ចកម្ពុជាមានការកើនឡើងជុំវិញ ៧% ជារៀងរាល់ឆ្នាំ។ កាលពីឆ្នាំ២០១៨ ក្នុងចំណោមប្រទេសអាស៊ាន គឺកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងគេ ហើយឆ្នាំ២០១៩ ក៏នៅតែបន្តឈរលើកំពូលតារាងខ្ពស់លើសគេដដែលក្នុងរង្វង់ ៧,១%។ ការរីកចម្រើនសេដ្ឋកិច្ចដ៏ខ្លាំងក្លារឹងមាំនេះ បានធ្វើឱ្យកម្ពុជាឈានទៅទទួលបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ ហើយអាចនឹងធ្វើឱ្យសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ អត្រាភាពក្រីក្រត្រូវបានកាត់បន្ថយមកក្រោម ១០% នាបច្ចុប្បន្ន។ ម្យ៉ាងទៀត កម្ពុជារក្សាបានសន្តិសុខការងារដោយអត្រាគ្មានការងារធ្វើប្រមាណ ០,៣% ប៉ុណ្ណោះ។

ប៉ុន្តែ ជាការគួរឱ្យសោកស្ដាយ រលកព្យុះនៃវិបត្តិជំងឺឆ្លងកូវីដ-១៩ បាននិងកំពុងបោកបក់មកលើសេដ្ឋកិច្ច និងសង្គម នៅក្នុងបណ្ដាប្រទេសស្ទើរតែទាំងអស់នៅទូទាំងពិភពលោក រួមទាំងកម្ពុជាយើងផងដែរ។ ការរីករាលដាលនៃមេរោគកូវីដ-១៩ និងវិបត្តិសេដ្ឋកិច្ចនេះ បានបង្កការគំរាមកំហែងយ៉ាងខ្លាំងក្លាដល់ការអភិវឌ្ឍដែលកម្ពុជាសម្រេចបានក្នុងរយៈពេល៣០ឆ្នាំចុងក្រោយនេះនៃប្រវត្តិសាស្ត្ររបស់ខ្លួន។ តាមការប៉ាន់ប្រមាណរបស់អ្នកសេដ្ឋកិច្ច ក៏ដូចជាស្ថាប័នអន្តរជាតិធំៗ បង្ហាញថាកាពប្រាកដប្រជានៃសេដ្ឋកិច្ចរបស់កម្ពុជាអាចនឹងធ្លាក់ចុះក្នុងរង្វង់ -១,៩% នៅឆ្នាំ២០២០នេះ។

ទោះជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ខ្ញុំព្រះករុណាខ្ញុំ សូមអះអាងសាជាថ្មីនូវការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការថែរក្សាឱ្យបាននូវភាពម្ចាស់ការលើការងារជាអាទិភាពចម្បងពីរ គឺ៖ **ទី១**-ការបន្តរក្សានូវស្ថិរភាពនយោបាយដែលជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងស្ថានការណ៍ និង**ទី២**-ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចឱ្យបានល្អប្រសើរទប់ស្កាត់អតិផរណានិងការឡើងថ្លៃទំនិញក្នុងទីផ្សារ និងការបន្តអនុវត្តឱ្យបានម៉ឺងម៉ាត់ ច្បាស់លាស់នូវភារកិច្ចចំនួនប្រាំដែល ខ្ញុំព្រះករុណាខ្ញុំបានដាក់ចេញកាលពីថ្ងៃទី១៤សីហា ឆ្នាំ២០២០កន្លងទៅនេះ ដើម្បីសន្តិភាព សុវត្ថិភាព សុខមាលភាពប្រជាជន និងការអភិវឌ្ឍន៍ប្រទេសជាតិ។

**ជនរួមជាតិជាទីស្នេហា**

បន្ថែមលើវិបត្តិដែលបង្កឡើងដោយជំងឺឆ្លងកូវីដ-១៩ សភាពការណ៍ពិភពលោកនៅតែបន្តប្រែប្រួលវិវឌ្ឍកាន់តែតឹងតែងស្មុគស្មាញ ប្រកបដោយគ្រោះថ្នាក់ បង្កឡើងដោយការប្រកួតប្រជែង

រវាងប្រទេសមហាអំណាចដើម្បីការពារផលប្រយោជន៍ រក្សាឥទ្ធិពលទាំងនយោបាយ យោធានិងសេដ្ឋកិច្ចរបស់ខ្លួន។ មហិច្ឆតាក្តោបក្តាប់និងដឹកនាំពិភពលោករបស់មហាអំណាចខ្លះ តាមរយៈការប្រកាន់យកនយោបាយឯកតោភាគីនិយម និងគាំពារនិយម បានជំរុញឱ្យសណ្តាប់ធ្នាប់អន្តរជាតិដែលផ្អែកលើច្បាប់និងប្រព័ន្ធពហុភាគីនិយម ដែលបានជួយរក្សាសន្តិភាព និងវិបុលភាពដល់ពិភពលោកអស់រយៈជិត៧៥ឆ្នាំកន្លងមកនោះ ទទួលរងសម្ពាធជាងពេលណាៗទាំងអស់។ នៅក្នុងបរិបទនេះ ប្រទេសមហាអំណាច និងលោកខាងលិចខ្លះបាន និងកំពុងសហការប្រទាក់ក្រឡាគ្នាជាប្រព័ន្ធ ក្នុងការដាក់សម្ពាធ រៀបសង្កត់ឱ្យកម្ពុជាដើរតាមគន្លងនយោបាយរបស់ខ្លួន ដូចដែលពួកគេធ្លាប់បានប្រព្រឹត្តមកលើកម្ពុជាកាលពីទសវត្សឆ្នាំ១៩៧០-១៩៨០ ដោយរំលោភបំពានលើគោលការណ៍សមភាពអធិបតេយ្យរវាងបណ្តារដ្ឋ និងគោលការណ៍មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងប្រទេសដទៃ ដែលមានចែងនៅក្នុងធម្មនុញ្ញ អ.ស.ប និងនៅក្នុងច្បាប់អន្តរជាតិ។

**ជនរួមជាតិជាទីស្នេហា**

អស់រយៈពេល ៤១ ឆ្នាំកន្លងមកនេះ ការធ្វើពលិកម្មដ៏ថ្លៃថ្លារបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាទូទាំងប្រទេស បានកែប្រែមាតុភូមិកម្ពុជាពីគំនរផេះផង់ឲ្យឈានមកដល់ដំណាក់កាលអភិវឌ្ឍន៍ប្រកបដោយមោទនភាព ទាំងក្នុងបុព្វហេតុការពារជាតិ ការពារការរស់ឡើងវិញរបស់ប្រជាជន ទាំងបុព្វហេតុសន្តិភាព និងបង្រួបបង្រួមជាតិ និងទាំងបុព្វហេតុស្តារ កសាង និងអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចកម្ពុជា។ ជាពិសេស កម្ពុជាបាននិងកំពុងតែបន្តបោះជំហានយ៉ាងរឹងមាំនៅលើមាគ៌ានយោបាយសន្តិសហវិជ្ជមាន អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ ជ្រោងខ្ពស់ស្មារតីជាតិនិយមការពារឯករាជ្យ អធិបតេយ្យជាតិ និងបូរណភាពទឹកដី។ សមិទ្ធផលដ៏ធំធេងអស្ចារ្យដែលកម្ពុជាទទួលបាននេះ មិនដែលទទួលនូវការសាទរ ឬសរសើរពីមហាអំណាចនិងប្រទេសលោកខាងលិចខ្លះ ដែលមានរបៀបវារៈនយោបាយតែមួយគត់ គឺទាញកម្ពុជាឱ្យធ្វើជាឈ្នាន់បម្រើមហិច្ឆតានយោបាយរបស់ពួកគេ។ លើសពីនេះទៀត ពួកគេមិនញញើតក្នុងការអនុវត្តនូវស្តង់ដាពីរចំពោះការវាយតម្លៃលើការអនុវត្តសិទ្ធិមនុស្សនៅកម្ពុជា និងប្រើប្រាស់បញ្ហាសិទ្ធិមនុស្សនេះ ជាឧបករណ៍នយោបាយ ឬជាលេសសម្រាប់ការលូកដៃចូលជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង រំលោភលើអធិតេយ្យភាព និងឯករាជ្យភាពរបស់កម្ពុជា និងបណ្តាប្រទេសទន់ខ្សោយផ្សេងទៀត។

កម្ពុជាយល់ច្បាស់ថា ការគោរពសិទ្ធិមនុស្ស ការលើកកម្ពស់សេរីភាពជាមូលដ្ឋាន ការប្រកាន់ខ្ជាប់នូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការលើកកម្ពស់នីតិរដ្ឋ និងនាំមកនូវសុខសន្តិភាព ស្ថិរភាព ភាពសុខដុមរមនា និងយុត្តិធម៌សង្គមជានិរន្តរ៍ នឹងជាការរួមចំណែកដ៏មានសារៈសំខាន់ដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្នផងដែរ។ តែយើងក៏ត្រូវតែចងចាំដែរថា មានសន្តិភាព ទើបធានាការអភិវឌ្ឍប្រកបដោយចីរភាព និងជីវភាពរស់នៅដ៏សុខសាន្ត សម្បូរសប្បាយរបស់ប្រជាជន មានសន្តិភាពទើបធានាដល់ការស្ថិតស្ថេរ និងរីកចម្រើននៃលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិសេរីភាព ហើយជោគជ័យនៃដំណើរការអភិវឌ្ឍន៍និងភាពរឹងមាំនៃប្រជាធិបតេយ្យ និងឥទ្ធិពលត្រឡប់មកវិញ

ធានានូវចីរភាពនៃសន្តិភាព។ បើយើងបាត់បង់សន្តិភាព នោះយើងនឹងត្រូវបាត់បង់អ្វីៗទាំងអស់។ ផ្លូវទៅមុខនឹងនៅតែជួបប្រទះឧបសគ្គជាច្រើនទៀត ប៉ុន្តែគ្មានឧបសគ្គណាដែលអាចមកកាំងដំណើររបស់ជាតិយើងបានឡើយ ឱ្យតែយើងរក្សាបាននូវការឯកភាពនិងសាមគ្គីភាពជាតិ ប្តេជ្ញាដាច់ខាតការពារសន្តិភាពដែលយើងសម្រេចបានមកដោយលំបាក ឲ្យនៅស្ថិតស្ថេរ រឹងមាំ គង់វង្សជានិច្ច មិនអនុញ្ញាតឲ្យកម្លាំងប្រតិកិរិយាណាមកបំផ្លាញទៅវិញបានឡើយ ទោះបីជាត្រូវបង់ដោយតម្លៃណាក្តី។

ខ្ញុំព្រះករុណា ខ្ញុំក៏សូមឆ្លៀតឱកាសនេះ សូមសម្តែងនូវការគោរព និងវាយតម្លៃខ្ពស់ចំពោះបងប្អូនប្រជាពលរដ្ឋគ្រប់ស្រទាប់ជាន់ថ្នាក់ ដែលបានធ្វើពលិកម្មទាំងកម្លាំងកាយ ចិត្តចូលរួមដល់ការថែរក្សាសន្តិភាព និងស្ថិរភាពនយោបាយ ការលើកស្ទួយអធិបតេយ្យជាតិ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាព និងនីតិរដ្ឋ និងការអភិវឌ្ឍ ប្រទេសជាតិ។ ព្រមជាមួយនេះ ខ្ញុំព្រះករុណាខ្ញុំក៏សូមថ្លែងអំណរគុណជាអនេកប្បការផងដែរ ចំពោះបណ្តាប្រទេសជាមិត្តជិតឆ្ងាយ ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិនានា ដែលបានជួយឧបត្ថម្ភដល់ប្រជាជនកម្ពុជាតាំងពីជំណាក់កាលសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍រៀងរហូតមក ហើយដែលកំពុងតែបន្តពង្រឹង និងពង្រីកថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាដើម្បីបុព្វហេតុ សន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍។

**ជនរួមជាតិជាទីស្នេហា**

ក្នុងនាមជាប្រទេសមួយដែលបានឆ្លងកាត់សង្គ្រាមបំផ្លិចបំផ្លាញដ៏រ៉ាំរ៉ៃ ក្រោយពីទទួលបាននូវការបង្រួបបង្រួមជាតិពិតតប្រាកដ សុខសន្តិភាពពេញលេញនៅទូទាំងប្រទេស និងការរីកចម្រើននៅលើគ្រប់វិស័យគួរជាទីមោទនៈ កម្ពុជាមិនភ្លេចមនោសញ្ចេតនារបស់ខ្លួនដែលមានចំពោះប្រជាជាតិរងគ្រោះផ្សេងទៀតនៅក្នុងពិភពលោក តាមរយៈការស្តែងចេញនូវការខិតខំចែករំលែកបទពិសោធន៍ ក្នុងការកសាង ថែរក្សា ការពារសន្តិភាព និងអភិវឌ្ឍប្រទេសជាតិ។ នេះគឺជាឆន្ទៈដ៏មោះមុតរបស់កម្ពុជាក្នុងការសម្តែងសាមគ្គីភាពជាអន្តរជាតិ និងរួមវិភាគទានដល់កិច្ចប្រឹងប្រែងរបស់សហគមន៍អន្តរជាតិដើម្បីបុព្វហេតុសន្តិភាព សន្តិសុខ និងមនុស្សធម៌នៅលើពិភពលោក។ កម្ពុជាមានមោទនភាពយ៉ាងក្រៃលែងក្នុងការចូលរួមរបស់ខ្លួន ក្នុងកិច្ចប្រតិបត្តិការរក្សាសន្តិភាពពិភពលោកក្រោមឆត្ររបស់អង្គការសហប្រជាជាតិ បើទោះជាមានការប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិតយ៉ាងណាក៏ដោយ។ ឆ្នាំនេះគឺជាឆ្នាំទី១៤ ដែលកម្ពុជាបានបញ្ជូនកងកម្លាំងសរុបចំនួន ៦,៨២២ នាក់ (ស្ត្រី ៣៦៩នាក់) ទៅបំពេញបេសកកម្មថែរក្សាសន្តិភាព អ.ស.ប នៅតំបន់បេសកកម្មចំនួន ១០ ក្នុងប្រទេស ៩ រួមមាន៖ ចាដ៍ ស៊ូដង់ ស៊ូដង់ខាងត្បូង អាហ្វ្រិកកណ្តាល លីបង់ ស៊ីប ស៊ីរី ម៉ាលី និងយេម៉ែន។ គិតត្រឹមដំណាច់ខែកក្កដានេះ កងកម្លាំងកម្ពុជាកំពុងបំពេញបេសកកម្មថែរក្សាសន្តិភាពមានចំនួន ៧៨៧នាក់ (ស្ត្រី៧៦ នាក់) នៅប្រទេសស៊ូដង់ខាងត្បូង លីបង់ ម៉ាលី អាហ្វ្រិកកណ្តាល និងយេម៉ែន។

**ជនរួមជាតិជាទីស្នេហា**

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរអរគុណដល់បងប្អូនជនរួមជាតិ ដែលបានគាំទ្រដល់សានយោបាយរបស់ខ្ញុំគឺ -អរគុណសន្តិភាព- ដែលខ្ញុំយល់ថា មានតម្លៃមិនសាបសូន្យ មិនថាកន្លងមក ថ្ងៃនេះ និងថ្ងៃក្រោយ។ មនុស្សទាំងអស់ត្រូវការសន្តិភាព លើកលែងតែពួកគេរកែប៉ុណ្ណោះដែលចង់បំផ្លាញសន្តិភាព។ -អរគុណសន្តិភាព- បានក្លាយទៅជាពាក្យស្លោករបស់ប្រជាជនដែលស្រឡាញ់សន្តិភាព។

នៅទីបញ្ចប់ខ្ញុំព្រះករុណាខ្ញុំ សូមប្រសិទ្ធពរជូនជនរួមជាតិជាទីស្នេហា សូមបានប្រកបដោយពុទ្ធពរទាំងបួន ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃសុក្រ ២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០២០

**ហ៊ុន សែន**